# Quizizz

## វិធីនានាក្នុងការតែងនិពន្ធ_១

Name : ____________________

Class : ____________________

Date : ____________________

1. វចនវិធី /វ៉ាច់ ចៈ ណាក់ វិ ធី/

- [ ] a) វិធីប្រើប្រាស់ពាក្យក្នុងអត្ថបទ ។ ពាក្យពេចន៍ ត្រូវប្រើឲ្យស្របតាមស្ថានភាព សង្គម បរិយាកាស តួនាទី ឋានៈ មុខរបរ និងប្រភេទនៃរឿង ផងដែរ ដូចជា ពាក្យពេចន៍របស់ កសិករ អាជីវករ មន្ត្រីរាជការ រាជសព្ទ សង្ឃសព្ទ ជាដើម ។
- [ ] b) វិធីប្រើប្រាស់ឃ្លាល្បះ ដើម្បីឲ្យស្នាដៃឬអត្ថបទ រឿង មានសម្រស់ទាក់ទាញអារម្មណ៍ បង្កើតបាននូវបរិយាកាស អណ្ដែតអណ្ដូង រំភើបរីករាយ កើតទុក្ខ ព្រួយបារម្ភ ... ។
- [ ] c) វិធីដែលអ្នកនិពន្ធធ្វើឲ្យអ្នកអានងឿងឆ្ងល់ចង់តាមដាន អានបន្តទៀត ។
- [ ] d) វិធីដែលអ្នកនិពន្ធប្រើសម្រាប់ធ្វើឲ្យតួអង្គមានទំនាស់វិបត្តិគ្នាខាងពាក្យសំដី កាយវិការ វាចាចិត្ត ។

2. វចនាវិធី /វ៉ាច់ ចៈ ណា វិ ធី/

- [ ] a) វិធីដែលអ្នកនិពន្ធធ្វើឲ្យអ្នកអានងឿងឆ្ងល់ចង់តាមដាន អានបន្តទៀត ។
- [ ] b) វិធីប្រើប្រាស់ឃ្លាល្បះ ដើម្បីឲ្យស្នាដៃឬអត្ថបទ រឿង មានសម្រស់ទាក់ទាញអារម្មណ៍ បង្កើតបាននូវបរិយាកាស អណ្ដែតអណ្ដូង រំភើបរីករាយ កើតទុក្ខ ព្រួយបារម្ភ ... ។
- [ ] c) វិធីដែលអ្នកនិពន្ធប្រើសម្រាប់ធ្វើឲ្យតួអង្គមានទំនាស់វិបត្តិគ្នាខាងពាក្យសំដី កាយវិការ វាចាចិត្ត ។
- [ ] d) វិធីដែលអ្នកនិពន្ធលើកយកតួអង្គ ព្រឹត្តិការណ៍ ធម្មជាតិ ទេសភាព សកម្មភាពមកពណ៌នារៀបរាប់ ឲ្យឃើញច្បាស់ ហាក់នៅនឹងភ្នែកស្រស់ៗ ។

liveworksheets.com

3. សន្ទេហវិធី /សន់ ទេ ហៈ វិ ធី/

- [ ] a) វិធីដែលអ្នកនិពន្ធប្រើសម្រាប់ធ្វើឲ្យតួអង្គមានទំនាស់វិបត្តិគ្នាខាងពាក្យសំដី កាយវិការ វាចាចិត្ត ។
- [ ] b) វិធីដែលអ្នកនិពន្ធលើកយកតួអង្គ ព្រឹត្តិការណ៍ ធម្មជាតិ ទេសភាព សកម្មភាពមកពណ៌នារៀបរាប់ ឲ្យឃើញច្បាស់ ហាក់នៅនឹងភ្នែកស្រស់ៗ ។
- [ ] c) វិធីដែលអ្នកនិពន្ធធ្វើឲ្យអ្នកអានងឿងឆ្ងល់ចង់តាមដាន អានបន្តទៀត ។
- [ ] d) វិធីដែលអ្នកនិពន្ធធ្វើការប្រៀបធៀបតួអង្គឬសកម្មភាពតួអង្គនៅក្នុងដំណើររឿងដើម្បីរំលេចនូវរូបារម្មណ៍ ។

4. បដិវិធី /ប៉ៈ ដិ វិ ធី/

- [ ] a) វិធីដែលអ្នកនិពន្ធលើកយកតួអង្គ ព្រឹត្តិការណ៍ ធម្មជាតិ ទេសភាព សកម្មភាពមកពណ៌នារៀបរាប់ ឲ្យឃើញច្បាស់ ហាក់នៅនឹងភ្នែកស្រស់ៗ ។
- [ ] b) វិធីដែលអ្នកនិពន្ធធ្វើការប្រៀបធៀបតួអង្គឬសកម្មភាពតួអង្គនៅក្នុងដំណើររឿងដើម្បីរំលេចនូវរូបារម្មណ៍ ។
- [ ] c) វិធីដែលអ្នកនិពន្ធធ្វើឲ្យតួអង្គពីរនាក់ឡើងសន្ទនាឆ្លើយឆ្លងគ្នាអំពីបញ្ហាអ្វីមួយ ។
- [ ] d) វិធីដែលអ្នកនិពន្ធប្រើសម្រាប់ធ្វើឲ្យតួអង្គមានទំនាស់វិបត្តិគ្នាខាងពាក្យសំដី កាយវិការ វាចាចិត្ត ។

liveworksheets.com

5. វណ្ណនាវិធី /វ៉ាន់ ណាក់ នា វិ ធី/

- [ ] a) វិធីដែលអ្នកនិពន្ធលើកយកតួអង្គ ព្រឹត្តិការណ៍ ធម្មជាតិ ទេសភាព សកម្មភាពមកពណ៌នារៀបរាប់ ឲ្យឃើញច្បាស់ ហាក់នៅនឹងភ្នែកស្រស់ៗ ។
- [ ] b) វិធីដែលអ្នកនិពន្ធធ្វើការប្រៀបធៀបតួអង្គឬសកម្មភាពតួអង្គនៅក្នុងដំណើររឿងដើម្បីរំលេចនូវរូបារម្មណ៍ ។
- [ ] c) វិធីដែលអ្នកនិពន្ធធ្វើឲ្យតួអង្គពីរនាក់ឡើងសន្ទនាឆ្លើយឆ្លងគ្នាអំពីបញ្ហាអ្វីមួយ ។
- [ ] d) វិធីដែលគេធ្វើឲ្យតួអង្គមួយរងទុក្ខទោសមានការឈឺចាប់ក្នុងខ្លួនឬមានវិប្បដិសារីអំពីរឿងអ្វីមួយដោយមានការនិយាយរំលឹកអំពីហេតុភេទឬរឿងរបស់ខ្លួនតែម្នាក់ឯង ។

6. ឧបមានវិធី /អុប ប៉ះ ម៉ាន វិ ធី/

- [ ] a) វិធីដែលអ្នកនិពន្ធធ្វើឲ្យតួអង្គពីរនាក់ឡើងសន្ទនាឆ្លើយឆ្លងគ្នាអំពីបញ្ហាអ្វីមួយ ។
- [ ] b) វិធីដែលអ្នកនិពន្ធធ្វើការប្រៀបធៀបតួអង្គឬសកម្មភាពតួអង្គនៅក្នុងដំណើររឿងដើម្បីរំលេចនូវរូបារម្មណ៍ ។
- [ ] c) វិធីដែលគេធ្វើឲ្យតួអង្គមួយរងទុក្ខទោសមានការឈឺចាប់ក្នុងខ្លួនឬមានវិប្បដិសារីអំពីរឿងអ្វីមួយដោយមានការនិយាយរំលឹកអំពីហេតុភេទឬរឿងរបស់ខ្លួនតែម្នាក់ឯង ។
- [ ] d) វិធីដែលអ្នកនិពន្ធប្រើដើម្បីធ្វើឲ្យដំណើររឿងកាន់តែឡើងទៅៗតាំងពីកម្រិតទាបរហូតដល់ខ្ពស់។

liveworksheets.com

7. សំវាទវិធី /សាំង វ៉ាទ វិ ធី/

- [ ] a) វិធីដែលគេធ្វើឲ្យតួអង្គមួយរង ទុក្ខទោសមានការឈឺចាប់ ក្នុងខ្លួនឬមានវិប្បដិសារីអំពី រឿងអ្វីមួយដោយមានការ និយាយរំលឹកអំពីហេតុភេទឬ រឿងរបស់ខ្លួនតែម្នាក់ឯង ។
- [ ] b) វិធីដែលអ្នកនិពន្ធប្រើដើម្បីធ្វើ ឲ្យដំណើររឿងកាន់តែឡើង ទៅៗតាំងពីកម្រិតទាបរហូត ដល់ខ្ពស់។
- [ ] c) វិធីដែលអ្នកនិពន្ធធ្វើឲ្យតួអង្គ ពីរនាក់ឡើងសន្ទនាឆ្លើយឆ្លង គ្នាអំពីបញ្ហាអ្វីមួយ ។
- [ ] d) វិធីដែលអ្នកនិពន្ធចែកដំណើរ រឿងជាដំណាក់ៗ ។ មានន័យថា កំពុងតែនិយាយ អំពីហេតុការណ៍ត្រង់នេះ ស្រាប់តែដំណើររឿងត្រូវ ផ្អាក ហើយចាប់រឿង ផ្សេងមក និយាយវិញម្តង ។

8. ឯកវាទវិធី

- [ ] a) វិធីដែលអ្នកនិពន្ធប្រើដើម្បីធ្វើ ឲ្យដំណើររឿងកាន់តែឡើង ទៅៗតាំងពីកម្រិតទាបរហូត ដល់ខ្ពស់។
- [ ] b) វិធីដែលអ្នកនិពន្ធចែកដំណើរ រឿងជាដំណាក់ៗ ។ មានន័យថា កំពុងតែនិយាយ អំពីហេតុការណ៍ត្រង់នេះ ស្រាប់តែដំណើររឿងត្រូវ ផ្អាក ហើយចាប់រឿង ផ្សេងមក និយាយវិញម្តង ។
- [ ] c) វិធីដែលអ្នកនិពន្ធប្រើក្នុង ដំណើររឿង ធ្វើឲ្យអ្នកអានផ្ទុះ សំណើចដោយមិនដឹងខ្លួន ។
- [ ] d) វិធីដែលគេធ្វើឲ្យតួអង្គមួយរង ទុក្ខទោសមានការឈឺចាប់ ក្នុងខ្លួនឬមានវិប្បដិសារីអំពី រឿងអ្វីមួយដោយមានការ និយាយរំលឹកអំពីហេតុភេទឬ រឿងរបស់ខ្លួនតែម្នាក់ឯង ។

9. វឌ្ឍមានវិធី /វាត់ ធះ មាន វិ ធី/

- [ ] a) វិធីដែលអ្នកនិពន្ធប្រើដើម្បីធ្វើឲ្យដំណើររឿងកាន់តែឡើងទៅៗតាំងពីកម្រិតទាបរហូតដល់ខ្ពស់។
- [ ] b) វិធីដែលអ្នកនិពន្ធចែកដំណើររឿងជាដំណាក់ៗ ។ មានន័យថា កំពុងតែនិយាយអំពីហេតុការណ៍ត្រង់នេះ ស្រាប់តែដំណើររឿងត្រូវផ្អាក ហើយចាប់រឿងផ្សេងមក និយាយវិញម្តង ។
- [ ] c) វិធីដែលអ្នកនិពន្ធប្រើក្នុងដំណើររឿង ធ្វើឲ្យអ្នកអានផ្ទះសំណើចដោយមិនដឹងខ្លួន ។
- [ ] d) វិធីដែលអ្នកនិពន្ធចេះលួងលោមបបោសអង្អែលធ្វើឲ្យអ្នកអានរីករាយរំភើបអណ្តែត អណ្តូងតាមដំណើររឿង ។

10. ឧបកថាវិធី /អុប ប៉ះ កៈ ថា វិ ធី/

- [ ] a) វិធីដែលអ្នកនិពន្ធប្រើក្នុងដំណើររឿង ធ្វើឲ្យអ្នកអានផ្ទះសំណើចដោយមិនដឹងខ្លួន ។
- [ ] b) វិធីដែលអ្នកនិពន្ធចែកដំណើររឿងជាដំណាក់ៗ ។ មានន័យថា កំពុងតែនិយាយអំពីហេតុការណ៍ត្រង់នេះ ស្រាប់តែដំណើររឿងត្រូវផ្អាក ហើយចាប់រឿងផ្សេងមក និយាយវិញម្តង ។
- [ ] c) វិធីដែលអ្នកនិពន្ធចេះលួងលោមបបោសអង្អែលធ្វើឲ្យអ្នកអានរីករាយរំភើប អណ្តែតអណ្តូងតាមដំណើររឿង ។
- [ ] d) វិធីដែលអ្នកនិពន្ធចេះធ្វើឲ្យដំណើររឿងមានភាពកម្សត់ក្រាត់ប្រាស និងការធ្វើទុក្ខទោសតួអង្គ ។

liveworksheets.com

11. ហាសវិធី

- [ ] a) វិធីដែលអ្នកនិពន្ធចេះលួងលោម បបោសអង្អែលធ្វើឲ្យអ្នកអានរីករាយរំភើប អណ្តែតអណ្តូងតាមដំណើររឿង
- [ ] b) វិធីដែលអ្នកនិពន្ធចេះធ្វើឲ្យដំណើររឿងមានភាពកម្សត់ ព្រាត់ប្រាស និងការធ្វើទុក្ខទោសតួអង្គ ។
- [ ] c) វិធីប្រើប្រាស់ពាក្យក្នុងអត្ថបទ ។ ពាក្យពេចន៍ ត្រូវប្រើឲ្យស្របតាមស្ថានភាព សង្គម បរិយាកាស តួនាទី ឋានៈ មុខរបរ និងប្រភេទនៃរឿងផងដែរ ដូចជា ពាក្យពេចន៍របស់ កសិករ អាជីវករ មន្ត្រីរាជការ រាជសព្ទ សង្ឃសព្ទ ជាដើម ។
- [ ] d) វិធីដែលអ្នកនិពន្ធប្រើក្នុងដំណើររឿងធ្វើឲ្យអ្នកអានផ្ទុះសំណើចដោយមិនដឹងខ្លួន ។

12. ប្រលោមវិធី

- [ ] a) វិធីដែលអ្នកនិពន្ធចេះលួងលោម បបោសអង្អែលធ្វើឲ្យអ្នកអានរីករាយរំភើប អណ្តែតអណ្តូងតាមដំណើររឿង ។
- [ ] b) វិធីដែលអ្នកនិពន្ធចេះធ្វើឲ្យដំណើររឿងមានភាពកម្សត់ ព្រាត់ប្រាស និងការធ្វើទុក្ខទោសតួអង្គ ។
- [ ] c) វិធីប្រើប្រាស់ពាក្យក្នុងអត្ថបទ ។ ពាក្យពេចន៍ ត្រូវប្រើឲ្យស្របតាមស្ថានភាព សង្គម បរិយាកាស តួនាទី ឋានៈ មុខរបរ និងប្រភេទនៃរឿងផងដែរ ដូចជា ពាក្យពេចន៍របស់ កសិករ អាជីវករ មន្ត្រីរាជការ រាជសព្ទ សង្ឃសព្ទ ជាដើម ។
- [ ] d) វិធីប្រើប្រាស់ឃ្លាល្បះ ដើម្បីឲ្យស្នាដៃឬអត្ថបទ រឿង មានសម្រស់ទាក់ទាញអារម្មណ៍ បង្កើតបាននូវបរិយាកាស អណ្តែតអណ្តូង រំភើបរីករាយ កើតទុក្ខ ព្រួយបារម្ភ ... ។

liveworksheets.com

13. ទារុណវិធី

- [ ] a) វិធីប្រើប្រាស់ពាក្យក្នុងអត្ថបទ ។ ពាក្យពេចន៍ ត្រូវប្រើឲ្យស្របតាមស្ថានភាព សង្គម បរិយាកាស តួនាទី ឋានៈ មុខរបរ និងប្រភេទនៃរឿងផងដែរ ដូចជា ពាក្យពេចន៍របស់ កសិករ អាជីវករ មន្ត្រីរាជការ រាជសព្ទ សង្ឃសព្ទ ជាដើម ។

- [ ] b) វិធីដែលអ្នកនិពន្ធចេះធ្វើឲ្យដំណើររឿងមានភាពកម្សត់ព្រាត់ប្រាស និងការធ្វើទុក្ខទោសតួអង្គ ។

- [ ] c) វិធីប្រើប្រាស់ឃ្លាល្បះ ដើម្បីឲ្យស្នាដៃឬអត្ថបទ រឿង មានសម្រស់ទាក់ទាញអារម្មណ៍ បង្កើតបាននូវបរិយាកាស អណ្ដែតអណ្ដូង រំភើបរីករាយ កើតទុក្ខ ព្រួយបារម្ភ ... ។

- [ ] d) វិធីដែលអ្នកនិពន្ធធ្វើឲ្យអ្នកអានងឿងឆ្ងល់ចង់តាមដាន អានបន្តទៀត ។

liveworksheets.com

## Answer Key

1. a
2. b
3. c
4. d
5. a
6. b
7. c
8. d
9. a
10. b
11. d
12. a
13. b

liveworksheets.com